THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
នាយក

ថ្ងៃទី 27 ខែមករា ឆ្នាំ 2021

បន្ទាប់ពីការសិក្សាតាមប្រព័ន្ធឌីជីថល 100% អស់រយៈពេលមួយឆ្នាំដោយសារជំងឺកូវីដ-19 រួចមក មណ្ឌលសាលារបស់យើងនឹងចាប់ផ្តើម*យឺតៗ និងដោយសុវត្ថិភាព*ទទួលសិស្សជាក្រុមៗ ដែលជ្រើសរើសការសិក្សាចម្រុះដោយផ្ទាល់ និងតាមប្រព័ន្ធឌីជីថល (ការសិក្សាតាមប្រព័ន្ធកូនកាត់)។ សិស្ស ដែលជ្រើសយកការសិក្សាតាមប្រព័ន្ធកូនកាត់ នឹងទៅសាលារៀនពីរថ្ងៃក្នុងមួយសប្តាហ៍ -- នៅថ្ងៃជាក់លាក់របស់ខ្លួនតែប៉ុណ្ណោះ -- ហើយសិក្សាតាមប្រព័ន្ធឌីជីថល នៅបីថ្ងៃទៀតដែលនៅសល់។

**សិស្ស PreK-2 ដែលគ្រួសារបានជ្រើសយកការសិក្សាតាមប្រព័ន្ធកូនកាត់ ក្នុងអំឡុងដំណើរការជ្រើសរើសដំបូង នៅរដូវឈើជ្រុះស្លឹក នឹងចាប់ផ្តើមលើកដំបូង នៅថ្ងៃចន្ទ ទី 22 ខែកុម្ភៈ។** បុគ្គលិកដែលជួយសិស្ស PreK-2 របស់យើង នឹងវិលត្រឡប់មកអគារសាលារៀនវិញនៅថ្ងៃចន្ទ ទី 8 ខែកុម្ភៈ ដើម្បីរៀបចំស្វាគមន៍សិស្សនៅថ្ងៃទី 22។ គ្រួសារសិស្ស PreK-2 ដែលបានជ្រើសរើសបន្តការសិក្សាតាមប្រព័ន្ធឌីជីថល 100% ក្នុងអំឡុងដំណើរការជ្រើសរើស នឹងមានឱកាសចូលរួមប្រព័ន្ធកូនកាត់នៅថ្ងៃក្រោយ។ ថ្នាក់ដឹកនាំនៃសាលារៀន នឹងទាក់ទងគ្រួសារសិស្ស PreK-2 ជាមួយព័ត៌មានលម្អិតជាក់លាក់។

ខណៈយើងចាប់ផ្តើមប្តូរមកការសិក្សាដោយផ្ទាល់ យើងអនុវត្តទាំងទំនុកចិត្តដោយដឹងថា យើងបានរៀបចំចាប់តាំងពីនិទាឃរដូវ ឆ្នាំ 2020 មកម្ល៉េះ។ គ្រប់សាលារៀនមានវិធានការសុវត្ថិភាពធំទូលាយ ដើម្បីការពារសុខភាព និងសុខមាលភាពរបស់សិស្ស និងបុគ្គលិករបស់យើង ដែលរួមមាន៖

- លក្ខខណ្ឌពិនិត្យរកជំងឺជាមុនសម្រាប់សិស្ស និងបុគ្គលិក
- ឧបករណ៍ការពារខ្លួន (PPE) សម្រាប់បុគ្គលិក និងសិស្ស ដើម្បីគាំទ្រលក្ខខណ្ឌពាក់ម៉ាស់ និងរបាំងមុខ តាមច្បាប់
- ការរៀបចំថ្នាក់រៀន និងបន្ទប់ទឹកថ្មី ដើម្បីលើកកម្ពស់គម្លាតសុវត្ថិភាព
- ខណ្ឌ plexiglass នៅក្នុងការិយាល័យ
- ទីតាំងដែលលាងដៃ និងទីតាំងទឹក នៅផ្លូវដើរ ដែលដំណើរការដោយគ្មានការប៉ះពាល់
- សញ្ញាចំនួនសិស្សអតិបរមានៅក្រៅបន្ទប់ថ្នាក់រៀននីមួយៗ និងសញ្ញាសុវត្ថិភាពទូទាំងសាលារៀន និង
- ពិធីសារពង្រឹងការសម្អាត ដោយប្រើប្រាស់ផលិតផលសម្អាតដែលអនុម័តដោយ EPA។

ការវាយតម្លៃលើប្រព័ន្ធខ្យល់ចេញចូល ក៏បានបំពេញរួចរាល់ផងដែរសម្រាប់សាលារៀនទាំងអស់ ហើយ ការជួសជុល និង/ឬការពង្រឹងដែលត្រូវការ កំពុងតែដំណើរការ។ បន្ទប់ណា ដែលយើងមិនអាចធានាបានថា

នឹងបំពេញនូវស្តង់ដារប្រព័ន្ធខ្យល់ចេញចូល ដោយសារតែមូលហេតុណាមួយនោះ នឹង<u>មិន</u>ត្រូវបានប្រើប្រាស់ឡើយ។ ខ្ញុំលើកទឹកចិត្តអ្នក ឲ្យចូលទៅ www.philasd.org/aes ដើម្បីស្វែងរកវីដេអូជំនួយ ពិធីសារសុវត្ថិភាព សំណួរ និងចម្លើយ ធនធានផ្សេងទៀត និងតំណភ្ជាប់នៃរបាយការណ៍ប្រព័ន្ធខ្យល់ចេញចូលនៅសាលារៀន។

ការសិក្សាដោយផ្ទាល់ អាចចាប់ផ្តើមជាដំណាក់កាលប្រកបដោយសុវត្ថិភាព ប្រសិនបើយើងគ្រប់គ្នាចូលរួមចំណែក បន្តមានភាពអត់ធ្មត់ និងបត់បែន និងរៀបចំផែនការជាមុន។ យើងនឹងបន្តចែករំលែកព័ត៌មានបច្ចុប្បន្នភាព ខណៈយើងខិតជិតដល់ការចាប់ផ្តើមយឺតៗ និងដោយសុវត្ថិភាព ដើម្បីឲ្យសិស្សរបស់យើងវិលត្រឡប់មកសិក្សាដោយផ្ទាល់វិញ។

ដោយសេចក្តីរាប់អាន!



William R. Hite Jr., Ed.D.
នាយក
មណ្ឌលសាលា Philadelphia